ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ៧ កើត ខែ បឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីពិធីចុះហត្ថលេខាលើឯកសារនានា និង
# ពិធីប្រកាសបើកជាផ្លូវការនូវគម្រោងហិរញ្ញប្បទានឥតសំណង
# សម្រាប់ការកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំ
# រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៨, ក្នុងដំណើរទស្សនកិច្ចរបស់លោកជំទាវ Gao Yan, អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋប្រជាមានិត ចិនមកព្រះរាជាណាចក្រកម្ពុជា, ពីថ្ងៃទី ១៨-១៩ ខែ មិថុនា ឆ្នាំ ២០១៨, ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម កម្ពុជា-ចិន លើកទី ៥ ជាមួយក្រសួងពាណិជ្ជកម្មកម្ពុជា, លោកជំទាវអនុរដ្ឋមន្ត្រី ជាមួយគណៈប្រតិភូ បានចូលជួបសំដែងការគួរសមជាមួយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានអញ្ជើញធ្វើជាអធិបតីជាមួយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៃកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានមួយចំនួន និងពិធីប្រកាសជាផ្លូវការនូវគម្រោងហិរញ្ញប្បទានឥតសំណង សម្រាប់ការកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាពិធីចុះហត្ថលេខាក្រោមអធិបតីភាពខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ជាមួយលោកជំទាវអនុរដ្ឋមន្ត្រី Gao Yan មានឯកសារត្រូវបានចុះហត្ថលេខាដូចខាងក្រោម÷

***១. លិខិតប្រគល់-ទទួល ថវិកាហិរញ្ញប្បទានឥតសំណងចំនួន ២ ៥០០ ០០០ ដុល្លារអាមេរិក សម្រាប់ការអនុវត្តគម្រោងកាត់បន្ថយយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅប្រទេសកម្ពុជា*** ។ ថវិកាហិរញ្ញប្បទានឥតសំណងនេះនឹងត្រូវបានប្រើប្រាស់សម្រាប់រួមចំណែកការងារបោសសម្អាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ សម្រាប់បម្រើវិស័យមនុស្សធម៌នៅប្រទេសកម្ពុជា ដែលនឹងត្រូវអនុវត្តដោយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

***២. កិច្ចព្រមព្រៀងសម្រាប់រៀបចំផែនការមេស្តីពីប្រព័ន្ធដឹកជញ្ជូននៅកម្ពុជា*** ។ តាមរយៈកិច្ចព្រមព្រៀងនេះ អ្នកជំនាញចិននឹងមកធ្វើការសិក្សា ដើម្បីរៀបចំផែនការមេស្តីពីប្រព័ន្ធដឹកជញ្ជូននៅកម្ពុជា ដោយផ្តោតជាពិសេសទៅលើប្រព័ន្ធផ្លូវគោក ផ្លូវដែក ផ្លូវទឹកផ្ទៃក្នុង ការដឹកជញ្ជូនតាមសមុទ្រ អាកាសចរស៊ីវិល និងឡជីស្ទិក ។

***៣. កិច្ចព្រមព្រៀងសម្រាប់ការអនុវត្តគម្រោងជួសជុលព្រះបរមរាជវាំងនៅអង្គរ-ខេត្តសៀមរាប*** ។ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួច ភាគីចិននឹងសហការជាមួយអាជ្ញាធរជាតិអប្សរា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីស្តារឡើងវិញនូវស្ថាបត្យកម្ម ការងារពាក់ព័ន្ធនឹងបុរាណវិទ្យា ការអភិរក្សចំលាក់ថ្ម ជាដើម ។

ឆ្លៀតឱកាសនោះដែរ, លោកជំទាវអនុរដ្ឋមន្ត្រី **Gao Yan** រួមជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** ក៏បាន រួមគ្នាប្រកាសបើកជាផ្លូវការនូវ គម្រោងហិរញ្ញប្បទានឥតសំណងពីប្រទេសចិន សម្រាប់ការកែលម្អបរិស្ថានសាលារៀន និង ការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំ ។

គម្រោងកែលម្អបរិស្ថានសាលារៀន និងការផ្គត់ផ្គង់សម្ភារៈបរិក្ខារអប់រំនេះនឹងសាងសង់អគារវិទ្យាល័យចំនួន ២៦ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូចំនួន ១ នៅនៅរាជធានីភ្នំពេញ, ១ នៅខេត្តកំពង់ចាម និង ១ ទៀតនៅខេត្តកណ្តាល ព្រមទាំងផ្គត់ផ្គង់បរិក្ខារចាំបាច់ផ្សេងៗទៀត ។

ពិធីចុះហត្ថលេខា និងពិធីប្រកាសជាផ្លូវការនាពេលនេះ គឺជាផ្លែផ្កាថ្មីៗទៀតកើតចេញពីភាពជាដៃគូយុទ្ធសាស្ត្រ គ្រប់ជ្រុងជ្រោយ កម្ពុជា-ចិន ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណ និងគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហា-សេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានកិច្ចសហការ ល្អ ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន សំដៅអភិវឌ្ឍន៍ប្រទេសកម្ពុជាលើគ្រប់វិស័យ ។

ជាសរុប, គិតចាប់ពីឆ្នាំ ២០០១ ដល់ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៨, រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានសន្យាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការមានទឹកប្រាក់សរុបចំនួនប្រមាណ **៥ ២៧៦ លាន ដុល្លារអាមេរិក** ក្នុងនោះ ហិរញ្ញប្បទានឥតសំណង និងឥណទានឥតការប្រាក់សរុបមានចំនួនប្រមាណ **១ ២៦១ លាន ដុល្លារអាមេរិក** ។